ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០០៥ គ.ជ.ប.ស.ស.រ

# សេចក្ដីសម្រេច
# ស្ដីពី
# ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០១០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់បោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៥៨៩ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ស្ដីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១១ សសរ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៦ ស្ដីពីការប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៦
- បានឃើញសេចក្ដីសម្រេចលេខ០២៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្ដីពីការដាក់ឱ្យប្រើបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្ដីសម្រេចលេខ០០៧ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥ ស្ដីពីការកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត



មហាវិថីសម្ដេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ, កម្ពុជា
Samdach Sothearos Blvd, Sangkat Tonle Bassac, Khan Chamkar Morn, Phnom Penh, Cambodia
ទូរសព្ទ : (+855) 23 23 52 53
អ៊ីមែល : info@nec.gov.kh

- បានឃើញសេចក្ដីសម្រេចលេខ០០៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៥ ស្ដីពីការដាក់ឱ្យប្រើបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ
- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦

## សម្រេច

### ប្រការ១.-

សេចក្ដីសម្រេចនេះកំណត់អំពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្ដល់សុពលភាពលើបញ្ជីបោះឆ្នោតឆ្នាំ២០២៦ ដើម្បីរៀបចំបញ្ជីបោះឆ្នោតសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៦ ឆ្នាំ២០២៧ និងតាមការកំណត់នៃច្បាប់។

ការរៀបចំ ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្ដល់សុពលភាពលើបញ្ជីបោះឆ្នោតឆ្នាំ២០២៦ ត្រូវអនុវត្តដោយអនុលោមទៅតាមបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ (ប.ន.ព.ច) ដែលដាក់ឱ្យប្រើដោយសេចក្ដីសម្រេចលេខ០០៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៥ លើកលែងតែលក្ខខណ្ឌទូទៅសម្រាប់ជ្រើសរើសសមាសភាពក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) ដែលមានចែងក្នុងចំណុច ២.៨.៣.៤ ត្រូវអនុវត្តតាមការសម្រេចដោយឡែករបស់ គ.ជ.ប។

### ប្រការ២.-

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្ដល់សុពលភាពលើបញ្ជីបោះឆ្នោតឆ្នាំ២០២៦ ត្រូវធ្វើចាប់ពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៦ រហូតដល់ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៧ ដូចបានកំណត់ក្នុងប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦។

### ប្រការ៣.-

ប្រជាពលរដ្ឋខ្មែរដែលមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក ដែលទើបដល់អាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៦ ឆ្នាំ២០២៧ ដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មី ត្រូវទៅជួប ក.ច.ប ដើម្បីបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត ស្របតាម ប.ន.ព.ច។

### ប្រការ៤.-

ប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ដែលមានបំណងកែតម្រូវទិន្នន័យជីវប្រវត្តិ (ប្ដូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ឬផ្លាស់ប្ដូរឯកសារចុះឈ្មោះបោះឆ្នោត) ឬ/និងដែលមានបំណងធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ (ថតរូប និងស្នាមម្រាមដៃ ដែលមិនធ្លាប់បានធ្វើបច្ចុប្បន្នភាពក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ) ត្រូវទៅជួប ក.ច.ប ដើម្បីបំពេញលក្ខខណ្ឌធ្វើបច្ចុប្បន្នភាពទិន្នន័យក្នុងបញ្ជីបោះឆ្នោតស្របតាម ប.ន.ព.ច។

**ប្រការ៥.-**

ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ ត្រូវអនុវត្តតាមលក្ខខណ្ឌ បែបបទ និងនីតិវិធីបន្ថែមដូចខាងក្រោម៖

៥.១ ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ទូទាំងប្រទេស ត្រូវអនុវត្ត ចាប់ពីថ្ងៃទី៧ ខែតុលា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦។

៥.២ ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ត្រូវបិទការិយាល័យចុះឈ្មោះបោះឆ្នោត ចំនួន ៤ (បួន) លើក ដើម្បីបើក កិច្ចប្រជុំជាមួយ ក.ច.ប ត្រួតពិនិត្យការអនុវត្តដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះ បោះឆ្នោត។ កិច្ចប្រជុំត្រួតពិនិត្យនេះត្រូវប្រព្រឹត្តទៅនៅថ្ងៃទី១២ ថ្ងៃទី២៩ ខែតុលា ថ្ងៃទី៩ និង ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៦។

៥.៣ ការកំណត់អាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ត្រូវគិតដល់ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹម ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៩)។

៥.៤ គ.ជ.ប ត្រូវអនុវត្តការផ្តល់លិខិតអញ្ជើញជូនប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ផ្លូវការឆ្នាំ២០២៥ ក្នុងគោលបំណងជំរុញដល់អ្នកដែលបានប្រើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលអស់សុពលភាព និងឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត (ឯ.អ) ក្នុងការចុះឈ្មោះបោះឆ្នោតកន្លងមក និងអ្នកដែលមានទិន្នន័យក្នុងបញ្ជីបោះឆ្នោតកត់ត្រា មិនបានត្រឹមត្រូវ ដើម្បីឱ្យមកកែតម្រូវទិន្នន័យជីវប្រវត្តិ ឬ/និងអ្នកដែលមិនបានធ្វើបច្ចុប្បន្នភាព ទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោតក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ ដើម្បីឱ្យមកធ្វើ បច្ចុប្បន្នភាពទិន្នន័យក្នុងបញ្ជីបោះឆ្នោតជាមួយ ក.ច.ប ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦។

៥.៥ អ្នកបោះឆ្នោតដែលត្រូវអញ្ជើញមកធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោតសម្រាប់ ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ គឺអ្នកចុះឈ្មោះបោះឆ្នោតក្នុង ឆ្នាំ២០១៦ និងឆ្នាំ២០១៧ ដែលមិនធ្លាប់បានធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ (ថតរូប ផ្តិតមេដៃ) ក្នុងបញ្ជីបោះឆ្នោត ពីមុនមក។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

អគ្គលេខាធិការ គ.ជ.ប ប្រធានលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានក្រុមចុះឈ្មោះបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៦

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

**កន្លែងទទួល៖**

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ខុទ្ទកាល័យឯកឧត្តមប្រធាន គ.ជ.ប
- គណបក្សនយោបាយ
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ